## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**លេខៈ ០១៤ សសថក**

## សមាគមស្អែកថ្មីកម្ពុ




# របាយការណ៍សង្ខេបប្រចាំឆ្នាំ (២០២២.២០២៣.២០២៤)

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**លេខ៖ ០១៤ សសថក**

## សមាគមស្អែកថ្មីកម្ពុជា

(Saèk Thmey Cambodge)

### លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប

**កម្មវត្ថុ៖** សំណើរសុំលោកប្រធានមន្ទីរជួយសម្របសម្រួលលិខិតគាំទ្ររវាងមន្ទីរអប់រំ យុវជន និងកីឡា ជាមួយនឹងសមាគមស្អែកថ្មីកម្ពុជា (STCA) ដើម្បីបន្តកិច្ចព្រមព្រៀងរយៈពេលបីឆ្នាំបន្តទៀត។

**យោង៖** លិខិតលេខ **០០១/ស ស ថ ក** ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការចុះបញ្ជីរបស់សមាគមស្អែកថ្មីកម្ពុជា។

-កិច្ចព្រមព្រៀងគម្រោងការរវាងមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ជាមួយនឹងសមាគមស្អែកថ្មីកម្ពុជា ចុះថ្ងៃព្រហស្បតិ៍ ១២ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២។

**តបតាមកម្មវត្ថុ** យោងតាមខាងលើខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា សមាគមស្អែកថ្មីកម្ពុជានឹងផុតកំណត់កិច្ចព្រមព្រៀងរវាងមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមស្អែកថ្មីកម្ពុជានៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៤។ ដើម្បីចូលរួមអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាឱ្យមានការរីកចម្រើនទៅលើគុណភាពអប់រំ និងសមស្របទៅតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា ទើបក្រុមព្រឹក្សាភិបាលរបស់សមាគមបានអនុម័តបន្តចុះកិច្ចព្រមព្រៀងជាមួយមន្ទីរអប់រំ យុវជន និងកីឡាក្នុងគោលបំណងដើម្បីពង្រឹងកម្មវិធីអប់រំ បណ្ដុះបណ្ដាលផ្នែកភាសាបារាំង ដែលមានកម្មវិធីអប់រំមូលដ្ឋានចំណេះដឹងភាសាបារាំង ឱ្យបានរីកចម្រើន និងមានការទទួលស្គាល់គុណភាពអប់រំ។

អស្រ័យដូចបានគោរពជម្រាបជូនខាងលើសូមលោកប្រធានមន្ទីរ មេត្តាជួយសម្រួលក្នុងការចេញលិខិតគាំទ្រដើម្បីបានចុះកិច្ចព្រមព្រៀងជាមួយនឹងមន្ទីរអប់រំ យុវជន និងកីឡា រយៈពេលបីឆ្នាំបន្តទៀត គឺឆ្នាំ(២០២៤-២០២៥- ២០២៦) ដោយក្ដីអនុគ្រោះ។

សូមលោកប្រធាន មេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃអង្គារ១៤ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧
សៀមរា ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២៤

**ប្រធានសមាគមស្អែកថ្មីកម្ពុជា**

**យ៉ាន់ ចន្ធី**

អាស័យដ្ឋាន៖ ភូមិត្រពាំងសេះ សង្កាត់ គោកចក ខេត្ត សៀមរាប លេខទូរស័ព្ទ ០៦៩ ២២៦ ៩៩៩

# មាតិកា


១. សេចក្ដីផ្ដើម

២. ឈ្មោះ សមាគម

៣. ម្ចាស់ជំនួយសំខាន់ៗ

៤. សកម្មភាព

៥. អាស័យដ្ឋាន

៦. ស្ថិតិបុគ្គលិកដែលកំពុងបម្រើការងារ

៧. ស្ថិតិ និងស្ថានភាពក្នុងមណ្ឌលៈ សមាគមស្អែកថ្មីកម្ពុជា

១.ចំនួនកុមារ និងយុវជនមើលថែក្នុងមណ្ឌល

២.ចំនួនកុមារ និងយុវជនក្រៅមណ្ឌល

៣. ចំនួនកុមារ និងយុវជនក្នុងមណ្ឌល និងក្រៅមណ្ឌល

៨.កន្លែងស្នាក់នៅក្នុងមណ្ឌល សមាគមស្អែកថ្មីកម្ពុជា

៩.រូបភាព និងសកម្មភាពមួយចំនួន នៃសមាគមស្អែកថ្មីកម្ពុជា ( ឆ្នាំ២០២២ - ២០២៤ )

១០.ប្រភេទជំនួយឧបត្ថម្ភដែលកុមារ យុវជន និងយុវតីទទួលបាន

១១. ទិសដៅអនុវត្តន៍បន្ត

១២. ការរំពឹងទុក និងគម្រោងទៅថ្ងៃអនាគត

១៣. សេចក្តីសន្និដ្ឋាន

- ផលវិជ្ជមាន
- ផលអវិជ្ជមាន

## ១. សេចក្តីផ្តើម

សមាគមស្អែកថ្មីកម្ពុជា គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ និងជាអង្គារមួយដែលជួយដល់កុមារ និងយុវជន យុវតីដែលមានជីវភាពខ្វះខាត ទីទាល់ក្រមកពីតាមជនបទដាច់ស្រយាល់ឱ្យមានឱកាសសិក្សារៀនសូត្រចាប់ពីថ្នាក់បឋមសិក្សា រហូតដក់ថ្នាក់វិទ្យាល័យ និងសាកលវិទ្យាល័យផងដែរ។ ហើយសមាគមស្អែកថ្មីកម្ពុជាក៏បានផ្តល់ជូនដល់សិស្សនៅក្នុងសមាគមដូចជា៖ ការស្នាក់នៅ អាហារហូបចុកមួយថ្ងៃ៣ពេល សម្ភារៈសិក្សា សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ និងផ្សេងៗទៀត។ សមាគមស្អែកថ្មីកម្ពុជា និងបុគ្គលិកទាំងអស់ក៏បានប្តាជ្ញាចិត្តថានឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីចូលរួមជាមួយនឹងមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអប់រំដល់សិស្សានុសិស្សទាំងអស់ឱ្យមានចំណេះដឹងប្រកបដោយគុណភាព។ ហើយនឹងធ្វើឱ្យប្រាកដថាកុមារទាំងអស់នៅក្នុងសមាគមមានឱកាសដូចក្មេងដទៃៗទៀតនៅ ក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់ការអប់រំនៅកម្រិតបឋមសិក្សា កម្រិតវិទ្យាល័យ និងសាកលវិទ្យាល័យផងដែរ។ លើសពីនេះទៅទៀត គោលដៅរបស់សមាគស្អែកថ្មីកម្ពុជា បានផ្តល់ជូននូវការបណ្តុះបណ្តាលវិស័យទេសចរណ៍ដល់សិស្សដែលនៅក្នុងសមាគមឱ្យមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកភាពមិនចេះអក្សរ ភាពអត់ការងារធ្វើ និងជួយកាត់បន្ថយនូវភាពក្រីក្រក្នុងសហគមន៍ផងដែរ។

## ២. ឈ្មោះ សមាគម : ״ សមាគមស្អែកថ្មីកម្ពុជា ״

## ៣. ម្ចាស់ជំនួយសំខាន់ៗ ៖

- **លោក** Hourst Pierre Denys Emille August Leon
- **លោក** Christophe Pflammatter
- អ្នកស្ម័គ្រចិត្ត ៖ **អ្នកស្រី យ៉ាន់ ចន្ធី**

## ៤. សកម្មភាព៖ កម្មវិធីអប់រំភាសាបរទេស

ការអប់រំ និងបណ្តុះបណ្តាលភាសាបរទេស និងវិស័យទេសចរណ៍ដល់សិស្សដែលនៅក្នុង និងក្រៅនៃសមាគមឱ្យមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកជួយកាត់បន្ថយនូវភាពក្រីក្រក្នុងសហគមន៍។

**៥. អាស័យដ្ឋាន៖** ផ្ទះលេខ............ផ្លូវ............ភូមិត្រពាំងសេះ សង្កាត់/ឃុំ គោកចក ស្រុក/ខណ្ឌ សៀមរាប រាជធានី/ខេត្ត សៀមរាប លេខទូរស័ព្ទ ០៦៩ ២២៦ ៩៩៩

- Email : contact@ecole-saekthmey.com
- វែបសាយ : www.ecole-saekthmey.com
- Facebook Page : Saèk Thmey ស្អែកថ្មី
- Telegram : 069 22 69 99

## ៦. ស្ថិតិបុគ្គលិកដែលកំពុងបម្រើការងារ ៖

| ស្ថិតិបុគ្គលិកដែលកំពុងបម្រើការងារ | | ស្រី | ប្រុស | សរុប |
|---|---|---|---|---|
| បុគ្គលិករបស់សមាគម | ខ្មែរ | ៣ | ៦ | ៩ |
| | បរទេស (គ្រូស្ម័គ្រចិត្ត) | ២ | ០ | ២ |
| បុគ្គលិកសរុប | | ៥ | ៦ | ១១ |

## ៧. ស្ថិតិ និងស្ថានភាពក្នុងមណ្ឌល៖ សមាគមស្អែកថ្មីកម្ពុជា

**១.ចំនួនកុមារ និងយុវជនមើលថែក្នុងមណ្ឌល**

កុមារ និងយុវជនមានអាយុ១៤ដល់២៥ឆ្នាំ៖ សរុប ៣៦នាក់ / ស្រី ១៤នាក់ ប្រុស ២២នាក់។

**២.ចំនួនកុមារ និងយុវជនក្រៅមណ្ឌល**

កុមារ និងយុវជនមាន៖សរុប ២២៥ នាក់/ ស្រី ៩៧នាក់ ប្រុស១២៨នាក់។

**៣. ចំនួនកុមារ និងយុវជនក្នុងមណ្ឌល និងក្រៅមណ្ឌល**

កុមារ និងយុវជនមាន៖ សរុប២៦១នាក់ / ស្រី ១១១នាក់ ប្រុស ១៥០នាក់។

## ៨.កន្លែងស្នាក់នៅក្នុងមណ្ឌល សមាគមស្អែកថ្មីកម្ពុជា

- បន្ទប់ការិយាល័យ ០១
- បន្ទប់គេងគ្រូស្ម័គ្រចិត្ត ០២
- បន្ទប់គេងបុគ្គលិក ០១
- បន្ទប់គេងសិស្សប្រុស ០២
- បន្ទប់គេងសិស្សស្រី ០១
- ថ្នាក់រៀន ០៣ បន្ទប់

បន្ទប់ទាំងអស់មានបំពាក់ដោយឧបករណ៍ដូចជា៖ កង្ហារ ទូរដាក់សៀវភៅ ឧបករណ៍ចាក់សម្លេង ឧបករណ៍បញ្ចាំងរូបភាព (ស្លាយ) និងឧបករណ៍ជាច្រើនទៀត...។

## ៩.រូបភាព និងសកម្មភាពមួយចំនួន នៃសមាគមស្អែកថ្មីកម្ពុជា (ឆ្នាំ២០២២ - ២០២៤)




*(សកម្មភាព សិស្សកំពុងរៀនភាសារបារាំង)*



(សកម្មភាព ឯកអគ្គរដ្ឋទូតនៃប្រទេសបារាំងប្រចាំនៅប្រទេសកម្ពុជាបានមកទស្សនា សមាគមស្អែកថ្មីកម្ពុជា)




(ថ្នាក់រៀនមានចំនួនបីថ្នាក់)



( ផ្ទះបាយ )



(បន្ទប់ការិយាល័យ)




( បន្ទប់សិស្សស្រី )




( បន្ទប់សិស្សប្រុស )



( ទីធ្លាមុខថ្នាក់រៀន )



( ផ្ទះជាន់ខាងលើសម្រាប់គ្រូស្ម័គ្រចិត្តស្នាក់នៅ)




(សកម្មភាព សិស្ស ទទួលប័ណ្ណសរសើរ)




(ប្រធានសមាគម ជាមួយនឹងគ្រូស្ម័គ្រចិត្ត)




(សកម្មភាព ភ្ញៀវមកទស្សនានៅសមាគម )




(សក្ខភាពសិស្សនៃសមាគមទទួលបានការងារក្រោយបញ្ចប់ការសិក្សាភាសាបារាំង)




(សកម្មភាព ចែកអំណោយដល់សិស្សក្នុង និងក្រៅនៃសមាគមស្អែកថ្មីកម្ពុជា)



(សកម្មភាព សប្បុរសជនផ្តល់អំណោយជូនដល់សមាគម)




(សកម្មភាព សិស្សជិះកង់នៅថ្ងៃ អាទិត្យ)




(សកម្មភាព គ្រូស្ម័គ្រចិត្តនាំសិស្សទៅទស្សនានៅសារៈមន្ទីរអន្តរជាតិអង្គរ)



(សកម្មភាព សិស្សនៃសាលាអង្គការស្អែកថ្មីកម្ពុជា កំពុងរត់ហាត់ប្រាណតាមដងស្ទឹងសៀមរាប)



(សកម្មភាព សិស្សក្រោយរត់ហាត់ប្រាណតាមដងស្ទឹងរូច)



(សកម្មភាព គ្រូ និងសិស្សនៃសមាគម ទៅទស្សនាតាមប្រាសាទ )



( សកម្មភាព សិស្សកំពុងតែទទួលទានអាហារជុំគ្នា )



( សកម្មភាពសិស្សជនជាតិបរទេស កំពុងតែចម្អិនអាហារពេលល្ងាចនៅផ្ទះបាយ )



(សកម្មភាព ការសម្រាកបន្ទាប់ពីដើរទស្សនាតាមប្រាសាទ)

## ១០.ប្រភេទជំនួយឧបត្ថម្ភដែលកុមារ យុវជន និងយុវតីទទួលបាន

១. ផ្តល់ការអប់រំភាសារបាំងដោយឥតគិតថ្លៃដល់កុមារ និង យុវជនទូទៅ

២. អនុវត្តការបង្រៀន និងរៀនក្នុងថ្នាក់រៀនរបស់សមាគម

៣.បង្រៀនចាប់ពីថ្នាក់ដំបូងសម្រាប់អ្នកមិនទាន់ចេះសោះរហូតដល់ថ្នាក់មធ្យមសិក្សា

៤. ផ្តល់ជូនដោយឥតគិតថ្លៃនូវអាហារូបត្ថម្ភ ភេសជ្ជៈ រួមទាំងកន្លែងស្នាក់នៅក្នុងសមាគមដល់សិស្សានុសិស្ស ដែលមានជីវិភាពខ្វះខាតមកពីជនបទដាច់ស្រយាលឬ មកពីខេត្តឆ្ងាយៗ

៥. ផ្តល់ជូនអាហារហូបចុករួមមានៈ អាហារពេលព្រឹក ពេលថ្ងៃត្រង់ និងល្ងាច

៦. ផ្តល់ជូនដោយឥតគិតថ្លៃនូវកុំព្យូទ័រដល់សិស្សានុសិស្សដែលស្នាក់នៅក្នុងសមាគម

៧. ផ្តល់ជូនដោយឥតគិតថ្លៃនូវសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃដល់សិស្សានុសិស្សដែលស្នាក់នៅក្នុងសមាគមដូចជា សម្លៀកបំពាក់ សម្ភារៈសិក្សា សាប៊ូបោកខោអាវ សាប៊ូកក់សក់ច្រាស ថ្នាំដុសធ្មេញ សម្លៀកបំពាក់ប្រចាំថ្ងៃ និងសេវាថែទាំសុខភាព។

## ១១. ទិសដៅអនុវត្តន៍បន្ត

សមាគមយើងនៅតែបន្តនូវការគ្រប់គ្រងរាល់សកម្មភាពដែលនឹងធ្វើអោយពួកគាត់ទាំងអស់គ្នា ទទួលបាននូវអនាគតដ៏ល្អប្រសើរគ្រប់ៗគ្នា និងផ្តល់ឱកាសអោយពួកគាត់សម្រេចចិត្តដោយខ្លួនឯងនូវអនាគតរបស់ពួកគាត់។

## ១២. ការរំពឹងទុក និងគម្រោងទៅថ្ងៃអនាគត

សមាគមស្នែកថ្មីកម្ពុជា មានគម្រោងនាំយកមកនូវការអប់រំដ៏ល្អ ជូនដល់ជនក្រីក្រទាំងឡាយណាដែលមានការខ្វះខាត ហើយនឹងផ្តល់ជូបនូវការអប់រំតាមផ្នែកនីមួយៗ ដោយគោរពទៅតាមគលការណ៍នៃការអភិវឌ្ឍន៍សហស្សវត្សន៍របស់សមាគមស្នែកថ្មីកម្ពុជា។

## ១៣. សេចក្តីសន្និដ្ឋាន

តាមរបាយការណ៍របស់សមាគមស្នែកថ្មីកម្ពុជាក្នុងរយៈពេលជាង១០ឆ្នាំមកនេះ សមាគមស្នែកកម្ពុជាអាចសន្និដ្ឋានបានថាគឺមានការជួបនូវផលវិជ្ជមាន និងផលអវិជ្ជមានមួយចំនួនដូចជា៖

➢ **ផលវិជ្ជមាន**

១. សិស្សនៃសមាគមស្នែកថ្មីកម្ពុជា មានទីកន្លែងស្នាក់នៅ មានអាហារហូបចុកមួយថ្ងៃ៣ពេល ហើយទទួលបានសម្ភារៈសិក្សា សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ និងសេវាថែទាំសុខភាពដោយឥតគិតថ្លៃ។

២. សិស្សទទួលបានសិក្សាអប់រំ យ៉ាងសកម្មក្រោមការគ្រប់គ្រងរបស់សមាគម។

៣. មានគ្រូជំនាញស្ម័គ្រចិត្តបរទេសចុះមកធ្វើការបង្រៀនផ្ទាល់នៅសសមាគម។

៤. សិស្សដែលបានបញ្ចប់ការសិក្សានៅសមាគមស្នែកថ្មីកម្ពុជា ពួកគាត់នឹងទទួលបានចំណេះខាងទេសចរណ៍ ភាសាជាតិដល់ថ្នាក់ទី១២ ឬសាកលវិទ្យាល័យ ភាសាបារាំង និងភាសាអង់គ្លេសផងដែរ។

៥. ជាពិសេស សមាគមស្នែកថ្មីកម្ពុជាបានចូលរួមសកម្មភាពជួយអភិវឌ្ឍន៍សង្គមក្នុងការកាត់បន្ថយភាពអត់ការងារធ្វើ ភាពក្រីក្រ ផ្តល់ឱកាសឱ្យកុមារ យុវជន និងយុវតីកម្ពុជាដែលមានជីវភាពខ្វះខាតបានសម្រេចគោលដៅនៅក្នុងថ្ងៃអនាគតរបស់ពួកគាត់។

➢ **ផលអវិជ្ជមាន**

១. សមាគមស្នែកថ្មីកម្ពុជាមានការខ្វះខាតនូវសម្ភារៈមួយចំនួនដូចជា៖ ថ្នាក់រៀន តុ កៅអី ក្តាខៀន។ល។

២. សិស្សថ្នាក់ភាសាបារាំងមិនសូវមានភាពទូលំទូលាយ។

៣. សមាគមមិនសូវមានជំនួយពីខាងក្រៅ។

៤. សមាគមត្រូវបង់សេវារៀនគួរឱ្យសិស្សប្រចាំខែនៅសាលារដ្ឋ។

ជាចុងក្រោយ និងជាដំណោះស្រាយនៃសមាគមស្នែកថ្មីកម្ពុជា សមាគមសូមសំណូមពរដល់ ក្រសួង និង មន្ទីរអប់រំ យុវជន និងកីឡា មេត្តាជួយសម្របសម្រួលឱ្យសមាគមស្នែកថ្មីកម្ពុជាមានការគាំទ្រក្នុងការធ្វើការផ្សព្វផ្សាយដោយទូលំទូលាយអំពីសមាគម និងមួយទៀតសូមសំណូមពរដល់ក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡា មេត្តាជួយសម្របសម្រួល ដល់សេវាបង់ថ្លៃរៀនគួរបន្ថែមនៅសាលារដ្ឋ ឱ្យមានការផតគិតថ្លៃចំពោះសិស្សនៃសមាគមស្នែកថ្មីកម្ពុជាដោយក្តីអនុគ្រោះ។

សមាគមស្នែកថ្មីកម្ពុជា និងបុគ្គលិកទាំងអស់សូមប្តាជ្ញាចិត្តថានឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីចូលរួមជាមួយនឹងមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអប់រំដល់សិស្សានុសិស្សទាំងអស់ឱ្យមានចំណេះដឹងប្រកបដោយគុណភាព។ ហើយនឹងធ្វើឱ្យប្រាកដថាកុមារទាំងអស់នៅក្នុងសមាគមមានឱកាសដូចក្មេងដទៃៗទៀតនៅ ក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់ការអប់រំនៅកម្រិតបឋមសិក្សា កម្រិតវិទ្យាល័យ និងសាកលវិទ្យាល័យផងដែរ។ លើសពីនេះទៅទៀត គោលដៅរបស់សមាគស្នែកថ្មីកម្ពុជា បានផ្តល់ជូននូវការបណ្តុះបណ្តាលវិស័យទេសចរណ៍ដល់សិស្សដែលនៅក្នុងសមាគមឱ្យមានប្រសិទ្ធភាព ដើម្បីចូលរួមជួយកាត់បន្ថយនូវភាពក្រីក្រក្នុងសហគមន៍។

ថ្ងៃអង្គារ១៤ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២៤

**សមាគមស្នែកថ្មីកម្ពុជា**

Saèk Thmey du Cambodge

លេខៈ ………………………………………………..

ថ្ងៃ…………… ខែ…… ឆ្នាំ…… ឆស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី….. ខែ……… ឆ្នាំ២០២…

បានឃើញ និងឯកភាព

**ប្រធានមន្ទីរ អប់រំ យុវជន និងកីឡា**

**អ្នកស្រី យ៉ាន់ ចន្ធី**